មានអារម្មណ៍ថា អ្វីគ្រប់យ៉ាងនៅក្នុងលោកនេះកំពុងតែព្យាយាមសម្លាប់ខ្ញុំ។

ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំត្រូវរស់នៅក្នុងពិភពមួយដែលគ្មានការពិត។ ទ្រាំទប់ទល់ រកមធ្យោបាយរក្សាជីវិត ដើម្បីតែនឹងមកអង្គុយឈឺចាប់។ តែ....ការតស៊ូនិងការរស់រានមានជីវិត ក៏ដូចជាជ័យជម្នះចុងក្រោយសក្តិសមនឹងឱ្យយើងហត់យ៉ាងនេះទេ?

ខ្លួនយើងផ្ទាល់គឺជាការប្រយុទ្ធ! ជាផ្នែកមួយនៃការប្រយុទ្ធនោះ ហើយខ្ញុំមិនមែនជាមនុស្សយន្តទេ និយាយមែន។

ដៃខ្ញុំស្វាបពោះ។ កូនរបស់ខ្ញុំទៅបាត់ហើយ គេរបូតបាត់ហើយតាំងពីប៉ុន្មានអាទិត្យមុន។ គេមិនទាន់បានមួយខែគ្រប់គ្រាន់ផងក៏ត្រូវចប់ទៅវិញ....តែកុំភ័យកូន! មិនអីទេ ការរស់រានមានជីវិតនៅលើលោកនេះសម្រាប់ម៉ាក់ គ្រាន់តែជាអនុស្សាវរីយ៍ព្រាលៗ។

ថ្ងៃនេះ ម៉ោងនេះ វិនាទីនេះ ម៉ាក់អង្គុយនៅលើជណ្តើរថ្មមួយនេះ រកនឹកមិនឃើញពីហេតុផលដើម្បីឱ្យខ្លួនឯងចង់ឃើញថ្ងៃស្អែកនោះឡើយ។

សម្រាប់ពេលនេះ គតិខ្ញុំប្រាប់មកថា យើងជាទាសករនៃសែនរបស់យើង គឺការវិវត្តជីវសាស្ត្រនិងការវិវឌ្ឍនៃវប្បធម៌ ហើយយើងក៏ជាទាសករនៃសេដ្ឋកិច្ច ទាសករនៃក្តីលោភរបស់យើងខ្លួនឯង។ ចំណែកឯអត្ថន័យតែមួយគត់ នៃជីវិតរបស់យើង គឺធ្វើអ្វីៗផ្គាប់ភ្នែកអ្នកដទៃ។

ខ្ញុំមិនដែលអាចធ្វើអ្វីមួយដែលមានអត្ថន័យសម្រាប់ខ្លួនឯងបាននោះទេ។

មានអារម្មណ៍ថា ឈឺពោះណាស់។ ខ្ញុំចាប់ផ្តើមដាក់ដៃមួយទៀតមកបន្ថែមកម្តៅទីនេះ។ ចិត្តខ្ញុំឈឺចាប់តាំងពីក្មេងមកធ្លាប់ហើយ។ តាំងពីពេលដែល ម្តាយរបស់ខ្ញុំបានស្លាប់ទៅ ខ្ញុំស្រែកយំយ៉ាងខ្លាំងនៅពេលអាយុត្រឹមតែប្រាំបីឆ្នាំ ខ្ញុំមិនចង់បាត់បង់គាត់ទេ ប៉ុន្តែពេលនេះខ្ញុំយល់ហើយថា ម្តាយខ្ញុំប្រហែលជាគាត់ហត់ពេក គឺហត់ដូចខ្ញុំឥឡូវនេះអ៊ីចឹង។

ក្នុងការចងចាំ ម៉ាក់តែងតែនាំខ្ញុំមកអង្គុយនៅលើជណ្តើរថ្ម ជាផ្ទះបុរាណចាស់ធំស្កឹមស្កៃ ក្នុងដីចម្ការដ៏ល្វឹងល្វើយរបស់យើង។ គ្រួសារយើងមានដីច្រើនណាស់ នៅមិនអស់នោះទេ ផ្ទះក៏ច្រើនកន្លែង តែម៉ាក់ខ្ញុំបែរជារើសយកការលាក់ខ្លួននៅចម្ការពេលគាត់ពិបាកចិត្តម្តងៗ។

គ្រួសារយើងគឺជាគ្រួសារដែលមានអ្វីគ្រប់បែបយ៉ាង។ មានតែអ្វីមួយប៉ុណ្ណោះ ដែលខ្ញុំមិនធ្លាប់មានគឺ ភាពរំភើបសប្បាយរីករាយ។

ប៉ាមិនឱ្យខ្ញុំមានមិត្តភក្ដិទេ។ ពួកគេក្រជាងនិងពិបាកទុកចិត្ត ម្ល៉ោះហើយ រហូតដល់ពេញវ័យ ខ្ញុំជាក្មេងស្រីឯកា មិនងាយនិយាយ ហើយមិនចេះញញឹម។

អូយ! ខ្ញុំស្រាប់ចាប់ផ្ដើមឈឺពោះខ្លាំងឡើងៗ។

«ជំទាវក្មួយ ទៅសម្រាក កុំនៅអង្គុយយូរពេកក្រពះមិនទាន់ជាស្រួលបួលទេ! ហើយស្បែកជើងកែងនេះកុំពាក់ ចាំពូទៅឡានយកស្បែកជើងរាបស្មើមកជូន!»

តែកុងឡាននេះជាមនុស្សប៉ាខ្ញុំបញ្ជូនមក ដូច្នេះពេលខ្លះគាត់ជួយលាក់លៀមខ្ញុំច្រើនមិនប្រាប់ប្ដីខ្ញុំថា ខ្ញុំទៅណាមកណាទេ។ រាល់ពេលខ្ញុំរត់ចេញមកអង្គុយនៅតាមសួនសាធារណៈម្នាក់ឯង គាត់បារម្ភបំផុត តែក៏បណ្ដោយខ្ញុំទៅព្រោះឃើញខ្ញុំមកតាំងពីតូច សង្ឃឹមថាមានគាត់ម្នាក់យល់ពីជីវិតគ្មានន័យរបស់ខ្ញុំ។

ខ្ញុំឱនសម្លឹងទៅស្បែកជើងកែងរបស់ខ្លួនឯង។ ទម្រាំខ្ញុំគេចចេញមកអង្គុយនៅកន្លែងនេះបាន ខ្ញុំមិនវិលទៅផ្ទះវិញដោយងាយៗទេ សង្ឃឹមទៅ។

ងាករកទូរសព្ទខ្ញុំ....ខ្ញុំលើកយកមក ប៉ុន្តែមិនមែនដើម្បីទទួលការហៅរបស់អ្នកណាទាំងអស់ ព្រោះខ្ញុំចុចបិទហើយ។ ក្នុងមួយថ្ងៃៗ ខ្ញុំមិនងាយបើកវាទេ បើសិនជាខ្ញុំមិនត្រូវប្រើ មិនត្រូវការចុចវា.....ខ្ញុំគ្មានអ្នកណាសម្រាប់ផ្ញើសារមក ក៏គ្មានអ្នកណាសម្រាប់ទាក់ទងមក គ្មាននរណាម្នាក់ដែលខ្ញុំរង់ចាំទេ។

ជីវិតដ៏គ្មានន័យមួយនេះ វានៅតែក្រៀមក្រំហើយកាន់តែក្រៀមក្រំខ្លាំងឡើង នៅពេលខ្ញុំដឹងថា មានមនុស្សម្នាក់បានមកចាប់បដិសន្ធិក្នុងផ្ទៃ។

ក្រោយមក រឹតតែក្រៀមក្រំទៅទៀត នៅពេលដែលខ្ញុំត្រូវបាត់បង់គេទៅវិញ។

ទីបំផុតខ្ញុំហាមាត់ស្រែក ព្រោះខ្ញុំទ្រាំការឈឺចាប់ផ្លូវកាយមិនបាន។

«កើតអី?»

សំឡេងមនុស្សម្នាក់លាន់មកក្បែរខ្ញុំ រួចហើយគេទម្លាក់សៀវភៅបីបួននោះចោលទៅលើជណ្ដើរថ្ម ស្ទុះមករកខ្ញុំ។

ខ្ញុំដកខ្លួនថយដោយទឹកមុខស្លេក។

ភាពធ្ងន់ធ្ងរស្ថិតនៅលើថ្ងាសរបស់ខ្ញុំ។ ដោយការឈឺចាប់ ខ្ញុំឈឺខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនបាននិយាយពាក្យនេះចេញទេ គ្រាន់តែខ្ញុំខាំធ្មេញ សម្លឹងមុខគេ។

នេះជាមនុស្សប្រុសម្នាក់សម្លឹងមកខ្ញុំដោយអាណិត.....

«មកជាមួយអ្នកណា? មានអ្នកណានៅក្បែរៗនេះទេ អ្នកផ្ទះ?!»

ប្រហែលជាឃើញសម្លៀកបំពាក់របស់ខ្ញុំឬក៏អ្វីម្យ៉ាង បានជាគេទាមទាររកញាតិខ្ញុំ បានជាគេគិតថាខ្ញុំមិនមកម្នាក់ឯង?

ភាពឡូយឆាយទាំងអស់ដែលខ្ញុំប្រើប្រាស់លើខ្លួនខ្ញុំ បានធ្វើឱ្យខ្ញុំគ្មានមិត្តតាំងពីក្មេង។ រហូតដល់អាយុ១៨ឆ្នាំ ថ្ងៃដែលខ្ញុំរៀបការជាមួយតារា ជាការបំពេញកាតព្វកិច្ចប៉ាខ្ញុំឱ្យដឹងតាំងពីអាយុដប់ពីរឆ្នាំមកថា ខ្ញុំនឹងកូនប្រុសពួកម៉ាកប៉ានឹងត្រូវរៀបការពេលធំឡើង។

កូនស្រីអ្នកមានដូចយើងតែងតែមានគូដណ្តឹងតាំងពីមិនទាន់ស្គាល់អ្វីទៅដែលហៅថាជីវិត កុំថាឡើយដល់សេចក្តីស្រឡាញ់ ដូច្នេះហើយយើងដាក់ច្រវាក់ទៅរៀនបរទេសដោយមានខ្ញុំកំដរតាមឃ្លាំ មិនអនុញ្ញាតឱ្យនិយាយសេពគប់ស្និទ្ធរកអ្នកណាបាន ថែមទាំងត្រូវត្រលប់មកផ្ទះវិញភ្លាមៗគ្រាន់តែប៉ាប្រាប់ថា ដល់ពេលអាចរៀបការបានហើយ។

«មានថ្នាំបំបាត់ការឈឺចាប់ទេ?»

ឈឺពេកខ្ញុំសួរទៅមនុស្សឈឺឆ្អាលម្នាក់នោះ ខណៈគេសម្លឹងខ្ញុំដោយកែវភ្នែកអាណិតហើយគ្រវីក្បាល។

«អូខេ! មិនអីទេ! កុំបារម្ភ!»

ខ្ញុំឈោងដៃប្រឹងក្រោកចាកចេញពីមនុស្សនេះ ប៉ុន្តែក្រោកភ្លាមក៏ត្រូវថយមកអង្គុយមកវិញភ្លាម ព្រោះដើរមិនរួច។ ខ្ញុំធ្វើមុខជូរ ព្រោះការឈឺចាប់ដែលកាន់តែសង្កត់ពេញពោះ។

«ខ្ញុំជូនទៅពេទ្យ ល្អទេ!»

«ទេ! ត្រឹមថ្នាំបំបាត់ឈឺបានហើយ!»

«ខ្ញុំមានថ្នាំ....ប៉ុន្តែខ្ញុំមិនឱ្យទេ!»

ខ្ញុំងើបមុខសម្លឹងមនុស្សនេះ។

គេញាក់ចិញ្ចើមបន្សល់ខ្ញុំ៖

«មិនមែនចេះតែលេបបានទេ យល់?»

អ្នកនាងដូចខ្ញុំកម្រមានអ្នកណានិយាយរបៀបស្មើគ្នាអ៊ីចឹងណាស់។ ប៉ាខ្ញុំសម្លុតខ្ញុំព្រោះអំណាចជាបិតា អ្នកបម្រើលន់តួព្រោះខ្លាចចិត្តខ្ញុំ ប្ដីខ្ញុំលួងលោមព្រោះយកចិត្តខ្ញុំ គ្រប់គ្នា.... បំពេញកាយវិការព្រោះអ្វីមួយដែលខ្ញុំទ្រលាន់ធុញណាស់ក្នុងជាតិនេះ។

ខ្ញុំមិនខ្វល់ជាយូរមកហើយជាមួយមនុស្សជុំវិញខ្លួន។

ម្នាក់នេះគេជាអ្នកណាមកនិយាយស្មើៗ....ខ្ញុំសម្លឹងគេ គេមានការបារម្ភខ្លាំងក្នុងការសម្លឹងដែលឱ្យមកខ្ញុំវិញ។

«ថ្នាំគេងឬថ្នាំបំបាត់ការឈឺចាប់ជារឿងធម្មតារបស់ខ្ញុំ!»

ខ្ញុំនិយាយតិចៗហើយលាដៃសុំគេ។

មនុស្សនេះលេបទឹកមុខពិបាកចិត្ត។ ជាលើកដំបូងក្រោយបាត់បង់ម៉ាក់ ខ្ញុំមិនដែលឃើញកែវភ្នែកព្រួយបារម្ភធុននេះសម្លឹងមកខ្ញុំទេ។

រហូតដល់ស្វាមីខ្ញុំខឹងខ្លាំង បោកកម្ទេចបណ្ដាកែវថ្នាំទាំងអស់ក្នុងផ្ទះចោល ក៏គេមិនដែលធ្វើឱ្យខ្ញុំខ្លាចបានសូម្បីតែព្រេចភ្នែកបន្តិចផងដែរ គ្មានអ្នកណាចោលភ្នែកមើលមកខ្ញុំបែបនេះទេ។

ក្រៅពីការសម្លុតរបស់ប៉ា កាយវិការខឹងសម្បាររបស់បងតារា និងភាពធ្វើគថ្លង់របស់បាវព្រាវក្នុងផ្ទះ បេះដូងមួយដែលខ្ញុំមាន វាខ្មៅខ្ទាំទៅហើយ វាធ្វើម៉េចនឹងក្ដិចឈឺឡើងមកបានដូចគេដូចឯងម្ដងទៀត?

មនុស្សម្នាក់មិនដែលរស់នៅជាខ្លួនឯងផង តើនាងចេះខ្លាចអ្វីទៅ?

គេគ្រវីក្បាលជាសញ្ញាមិនឱ្យថ្នាំមកខ្ញុំទេ។

«អូខេ ខ្ញុំទៅផ្ទះ!»

គេនោះពាំងពីមុខខ្ញុំហើយនិយាយ៖

«ផ្ទះនៅណា? អ្នកណាជូនទៅ?»

ខ្ញុំមិនតបបានទេ តែអាចមើលភ្នែកគេដោយសារត្រចៀកខ្ញុំចេញខ្យល់ គ្រប់យ៉ាងប្រែពណ៌ ខ្ញុំឃើញមុខគេងងឹត ក្បាលខ្ញុំស្ពឹក ហើយរាងកាយខ្ញុំស្រុញដួលចុះ។

ដៃអ្នកណាម្នាក់ត្រកងខ្ញុំបានជាខ្ញុំមិនរេលទៅលើថ្ម។

ពេលវេលារំលងព្រោះខ្ញុំបិទភ្នែកដែលសើមដោយជលនេត្រ។ ខ្ញុំមិនត្អូញមួយអឺះទេ ក៏ភាពចុកចាប់ក្នុងពោះបានបញ្ចប់ថយបន្តិចម្តងៗ។ ក្លិនអ្វីមួយ បានជួយសម្រាលដង្ហើមនិងផ្តល់អុកស៊ីសែនស្មើមកខ្ញុំវិញ។ របស់នេះខ្ញុំមិនដែលមានទេ តែខ្ញុំដឹងថា អ្នកបម្រើក្នុងផ្ទះប្រើវា។ ធ្លាប់មាន គេប្រាប់ខ្ញុំថាវាជាប្រេងកូឡា។

«លាបវានៅលើថ្ងាសខ្លួនទៅ!»

គេបង្គាប់មក។

«ខ្ញុំបើកភ្នែកមិនរួចទេ» ខ្ញុំនិយាយតិចៗព្រោះទោះស្បើយវិលមុខ តែពិតជាបើកភ្នែកមិនរួចមែនដោយសារផ្សាភ្នែក។

«ក្លិនប្រេងខ្យល់អ៊ីចឹងហើយ! បិទភ្នែកបន្តិចសិនទៅកុំប្រញាប់បើក! ហើយលូកមកលាបថ្ងាសខ្លួនឯងទៅ!»

ខ្ញុំធ្វើតាមគេប្រាប់។ ប៉ុន្មាននាទីរំលងផុតទៅខ្ញុំបើកភ្នែកមកវិញ ហើយឃើញគេនៅអង្គុយទន្ទឹមគ្នា ខ្ញុំញញឹមព្រោះឃើញគេញញឹមដែលឃើញទឹកមុខខ្ញុំភ្លឺថ្លាឡើងវិញ។

អត់ដឹងទេថា ជាមួយមនុស្សថ្មីដែលទើបចូលចំពោះមុខ យើងនិយាយគ្នា បានយូរប៉ុនណាហើយទេ ប៉ុន្តែដឹងត្រឹមថាត្រលប់មកផ្ទះថ្ងៃនេះសប្បាយចិត្តប្លែក។ អ្នកផ្ទះតាមកេះគ្នា លបមើលខ្ញុំញ៉ាំ Dinner បានច្រើន ហើយសូម្បីតែផ្លែឈើដែលគេចិតយកមកដល់បន្ទប់ពេលព្រឹកតែងតែយកត្រលប់ទៅវិញពេញៗចានស្អែកថ្មី គេនាំគ្នាឆ្ងល់ថាហេតុអីសល់តែចានទទេ។

ដូចប្រាប់អ៊ីចឹង នេះជាពេលដំបូងមួយនៃជីវិតដែលមានអារម្មណ៍ថា ចង់មានថ្ងៃស្អែក។ ចិត្តខ្ញុំនៅចិញ្ចឹមឆ្ងល់ថា តើម្នាក់ប្រុសនោះជាអ្នកណា? គេឈ្មោះអ្វី? សូម្បីតែឈ្មោះគេក៏ខ្ញុំអត់បានសួរផង។

ជាមួយជីវិតមួយនេះ មានទំនាក់ទំនងជាមួយអ្នកផងអន់ថយបំផុតស្រាប់ហើយ។ ថ្មើរណេះខ្ញុំមកផ្ទះវិញ ទើបតែនឹកឃើញចង់ដឹងអំពីគេ?

ទោះបីជាយ៉ាងណា ភ្នំពេញតូចប៉ុណ្ណេះ គង់តែគ្មានអ្វីមួយអាចរារាំងយើងទាំងពីរមិនឱ្យចួបគ្នាជាថ្មីបាននោះទេ។ ដោយសុទិដ្ឋិនិយម ខ្ញុំរកគេឃើញនៅក្នុងបណ្តាញសង្គម។ គេឈ្មោះវណ្ណឌី ជានិស្សិតសិក្សានៅផ្នែកឱសថនៅសាលាមួយនាខណ្ឌទួលគោក ក្បែរសួនដែលខ្ញុំបានទៅអង្គុយនោះ។

ខ្ញុំឈែតទៅគេ ដើម្បីអរគុណរឿងពីល្ងាច ប៉ុន្តែដល់បីបួនថ្ងៃក្រោយមកទើបគេឃើញឆែត ហើយតបវិញ។ ក្រោយៗមក យើងក៏បានចួបគ្នានៅទីសួនដដែលនោះ។ ពីម្តងទៅម្តង ទំនាក់ទំនងខ្ញុំនិងនិស្សិតរឹតតែជិតដិត រាល់ពេលដែលខ្ញុំធ្វើពុតប្រាប់ប្តីថាចេញទៅម៉ាស្សាមុខ ឬហាងកែសម្រស់ផ្សេងៗ តាមពិតខ្ញុំមានពេលវេលាយ៉ាងល្អជជែកត្រូវគ្នាបំផុតជាមួយវណ្ណឌី នៅសួននោះ ដោយមានពូ driver ជួយលាក់ឱ្យ។

ពេលបាយល្ងាចនេះ ដូចភាពគ្មានជីវិតជីវ៉ារាល់ដងក្នុងផ្ទះនេះ។ ប្តីខ្ញុំជាអ្នកជំនួញ គេរវល់ខ្លាំងណាស់ រវល់មិនដឹងថានឹកឃើញមុខប្រពន្ធឬអត់ផង។ ជាទូទៅម៉ោងប្រាំបីកន្លះយប់ទើបបងតារាមកដល់ផ្ទះ គឺទៀងពេលណាស់ គាត់ចូលមកតុបាយតែម្តងទាំងអាវធំ ឬឈុតជាCEO ដ៏ឡូយឆាយរបស់គេ។

ដូច្នេះមុនម៉ោង៨កន្លះ ខ្ញុំតែងមានពេលច្រើនសម្រាប់ចេញទៅញ៉ាំអាហារពេលល្ងាចនៅតាមផ្លូវ ដែលតាំងពីក្មេងមកប៉ាខ្ញុំមិនដែលអនុញ្ញាតនោះទេ។ គឺទៅជាមួយវណ្ណឌី។

ដូចយ៉ាងពេលល្ងាចមិញនេះ យើងអង្គុយនឹងតុជ័រទាបមួយ ជាមួយកៅអី២តូចៗ ដូចសម្រាប់កុមារអង្គុយ ប្របមាត់ទន្លេ ក្រោមដើមផ្កាត្របែកព្រៃរង់ចាំម្ហូបខ្ចៅខ្យងរបស់យើង ដែលខ្ញុំចូលចិត្ត។

មានយុវវ័យជាច្រើនដែលខ្លះក្មេងៗឬក៏ចាស់ជាងយើង ខ្លះអង្គុយជជែកគ្នាជាក្រុម ខ្លះមានគូ ប៉ុន្តែខ្ញុំនឹងវ៉ាន់ឌីនៅឆ្ងាយពីគេបន្តិច ពួកយើងងាយជជែកគ្នាច្រើនរឿង ជាពិសេសគេនិយាយរឿងនៅស្រុកកំណើតគេប៉ាម៉ាក់គេនិងបងគេដែលជាប់បួកទៅរៀននៅស្រុកក្រៅរួចការប្រពន្ធនៅទីនោះ។ល។

«ម៉េចក៏ញ៉ាំរហូតអ៊ីចឹងអត់មានរឿងនិយាយវិញខ្លះទេ?» វណ្ណឌីបង្អាក់ខ្ញុំដែលញ៉ាំមិនឈប់ ហើយរីករាយនឹងស្តាប់រឿងទាំងអស់របស់គ្រួសារគេ ដោយគ្មានរឿងប្រាប់គេវិញទេ។

«ខ្ញុំចូលចិត្តកន្លែងនេះ ខ្យងនិងចំណីអស់នេះ!»

«មិនដែលបានមកទេ?»

ខ្ញុំគ្រវីក្បាលជំនួសចម្លើយ ទឹកមុខរបស់គេនិងទឹកមុខរបស់ខ្ញុំ ពួកយើងគិតដូចគ្នាណាស់ សូម្បីតែអារម្មណ៍ដែលយើងផ្សារភ្ជាប់គ្នាក៏ដូចគ្នា គឺគេប្រាកដជាយល់ហើយជីវិតខ្ញុំមុនចួបគេសោះកក្រោះបែបណា?

«ខ្ញុំទិញរបស់មួយឱ្យពៅ!»

ខ្ញុំភាំងពេលដែលគេហៅខ្ញុំដូច្នេះ ពីព្រោះនេះមិនមែនជាឈ្មោះពិត ជាឈ្មោះដែលខ្ញុំកុហកវ៉ាន់ឌី ហើយខ្ញុំបង្កើតហ្វេសប៊ុកប្រើឈ្មោះក្លែងក្លាយនេះ ដើម្បីលេងឈែតជាមួយគេ។ ដោយសារខោអាវខ្ញុំថ្លៃៗ ខ្ញុំកុហកគេថា ខ្ញុំធ្វើការឱ្យហាងអនឡាញខោអាវប្រេនមួយ។

និយាយពិតទៅខ្ញុំគ្មានហ្វេសប៊ុកទេ នៅមុនពេលដែលស្គាល់គេ។

ខ្ញុំបើកភ្នែកធំៗសម្លឹងដង្កៀបសក់មួយ ឃ្យូតតូច មានត្បូងភ្លឺរន្ទាល។ ហើយមិនដឹងថា ខ្ញុំកំពុងតែញញឹមរបៀបណាទេ បានជាគេញញឹមតាម។

«ខ្ញុំកៀបឥឡូវ!»

នេះដើម្បីលើកទឹកចិត្តគេ ខ្ញុំថាហើយក៏ច្បូតសក់មកចំហៀង ដៃកៀបវាឡើងតែម្តង។ មិនដឹងថាយ៉ាងម៉េចទេ គេឈប់ញញឹមហើយសម្លឹងខ្ញុំឡើងភ្លឹក។ ពន្លឺភ្នែករបស់គេ ធ្វើដូចជាខ្ញុំនេះស្អាតជាងអ្នកណាអ្នកណាទាំងអស់នៅក្នុងពិភពលោកយើង។

បេះដូងខ្ញុំលោតភឹប!

ខ្ញុំញញឹមផងស្ទើរមិនញញឹមផងគឺចេញចំហាយក្តៅពេញខ្លួន ម្យ៉ាងដង្ហើមនេះគឺលោតញាប់ខ្លាំងណាស់។ បេះដូងសរសៃសស្វងអស់នេះ វាមិនដែលលោតរន្ថើនបែបនេះទេ វាគាំងស្ងៀមជាយូរណាស់មកហើយ។ សូម្បីតែពេលដែលខ្ញុំរៀបការឬមួយក៏ពេលណាផ្សេងទៀត។

ហេតុអីបានលោតលឿន អៀននិងមានសម្ពាធ ថែមលាយឡំភាពកក់ក្តៅ ដល់ថ្នាក់ខ្ញុំលែងចង់សម្លឹងភ្នែករបស់គេ?

បេះដូងខ្ញុំរស់ឡើងវិញហើយមែនទេ ខ្ញុំមិនមែនជាមនុស្សសម្បកដូចកាលពីប៉ុន្មានឆ្នាំមុនទៀតទេមែនទេ?

ខ្ញុំលែងញញឹម ហើយលបលួចគិតអំពីជីវិតរបស់ខ្លួនឯងស្ងាត់ៗ។ ខ្ញុំតែងមានអារម្មណ៍ស្ពឹកៗ មិនចង់ស្តីមិនចង់ស្តាប់ ខ្ជិលគិត និងខ្ជិលស្វែងយល់ពីអ្វីគ្រប់យ៉ាង។ នៅក្រោយពេលរៀបការជីវិតរបស់ខ្ញុំ ហាក់ដូចជាលែងមានប្រតិកម្មដោយអារម្មណ៍ ខ្ញុំលែងផ្សារភ្ជាប់ខ្លួនឯងទៅនឹងពិភពលោកជុំវិញនេះ។ ប៉ាធ្លាប់នាំខ្ញុំទៅពេទ្យចិត្តសាស្ត្រមុនរៀបការ ព្រោះខ្ញុំមិនសប្បាយក៏មិនកើត

ទុក្ខ ពេទ្យធ្លាប់ដាស់តឿនឱ្យរកចួបអ្នកណាដែលខ្ញុំអាចមានអារម្មណ៍សប្បាយចិត្តជាមួយ តែគ្មានមនុស្សនោះទេនៅលើលោកយើងនេះ។

«ម៉ែ សុំថតរូបឱ្យមួយ!»

គេចង់ថតរូបខ្ញុំ។ សំណូមពរនេះទាញអារម្មណ៍ខ្ញុំចាកចេញពីអតីត។

«បានទេ?» គេសួរផ្ទួនមក។

ខ្ញុំងក់ក្បាល។ គេលូកយកទូរសព្ទមកភ្លាមហើយឧទាន៖

«អូយអស់ថ្មបាត់ហើយ! ម៉ែ....ឱ្យទូរសព្ទមកខ្ញុំថតឱ្យ!»

ខ្ញុំភាំងពេលគេសួររកទូរសព្ទខ្ញុំ។

គេក៏ភាំងលើកចិញ្ចើមរង់ចាំខ្ញុំ។ ខ្ញុំត្រូវគ្រវីក្បាលយឺតៗហើយទម្លាក់ទឹកមុខ៖

«អត់បានយកទូរសព្ទមកទេ!»

គេក៏ទម្លាក់ទឹកមុខដូចគ្នា។ ប្រហែលជាឆ្ងល់ថា ហេតុអីសម័យនេះហើយមានអ្នកអត់យកទូរសព្ទមកតាមទៀត?

ស្គាល់វណ្ណឌី ខ្ញុំស្គាល់ពិភពលោកខាងក្រៅ។ ខ្ញុំទើបនឹងដឹងថា ខ្លួនខ្ញុំខុសពីគេទាំងអស់នៅក្នុងសម័យកាលនេះ ខ្ញុំជាមនុស្សមកពីពិភពផ្សេង ជាពិភពមួយដែលចម្លែកគ្មានអ្នកណាគេយល់នោះទេ។

សូម្បីតែខ្ញុំក៏មិនយល់អំពីវាដែរ រហូតដល់ពេលដែលខ្ញុំបានចួបគេ បានខ្ញុំដឹងថាមានពិភពលោកមួយទៀតដែលខ្ញុំគួរតែចេញមករស់នៅជាយូរមកហើយ។

នៅក្នុងគំនាបរបស់ប៉ាខ្ញុំ ឬក៏ស្វាមីនៃមង្គលការរៀបចំមួយ ដែលបេះដូងខ្ញុំមិនត្រូវការនោះមិនមែនជាជីវិតរបស់ខ្ញុំទេ។

«ភ្លេចទូរសព្ទមែន?» គេសួរ ធ្វើឱ្យខ្ញុំងើបមុខធ្វើភាំងៗទៀត។

«អត់ទេ គឺមិនដែលយកតាមខ្លួន! រំខាន!»

«អ្ហាក់ មានអ្នកគិតអ៊ីចឹងដែរ? ទូរសព្ទក៏សំខាន់ មានការអីក្រែងប្រើហៅរកអ្នកនេះអ្នកនោះបាន!»

ខ្ញុំជាមនុស្សមិនមានពាក្យសម្ដីច្រើនទេ តែមានរឿងខ្លះខ្ញុំត្រូវកុហកគេ។

«ធ្វើការឱ្យគេ ថៅកែស្រីខ្ញុំពូកែទូរសព្ទមកប្រើមិនដឹងពេលវេលា ដូច្នេះហើយខ្ញុំមិនចង់កាន់ទូរសព្ទទៅក្រៅម៉ោងធ្វើការ!»

អូខេគេងក់ក្បាលទទួលយកហេតុផលនេះ។

យប់នេះត្រលប់មកផ្ទះវិញ ខ្ញុំអង្គុយញញឹមសម្លក់ម្ហូបអាហារ ហើយញ៉ាំទៀតដូចមិនដែលបានញ៉ាំ ព្រោះនៅពេលដែលបេះដូងពោរពេញទៅដោយមនោសញ្ចេតនា ខ្ញុំពិតជាទទួលយកបាននូវរសជាតិទាំងអស់ដែលស្ថិតនៅចំពោះមុខខ្ញុំ ទទួលស្គាល់ថា ម្ហូបមើលទៅឃើញស្អាតទាក់ទាញគួរឱ្យចង់ភ្លក់ រសជាតិម៉ាត់ទីមួយ ធ្វើឱ្យយើងចង់បន្តទៅដល់ម៉ាត់ទីពីរ។

អ្នកបម្រើគ្រប់គ្នាសម្លឹងមកខ្ញុំដោយចម្លែក។

ពិសេសប្ដីរបស់ខ្ញុំ.....

«ថ្ងៃនេះរីងាសប្បាយចិត្តរឿងអី?»

ខ្ញុំទម្លាក់ស្នាមញញឹមចោលហើយងើបមុខសម្លឹងមនុស្សប្រុសនៅចំពោះមុខ ដែលខ្ញុំគិតថារូបគេ វត្តមានរបស់គេតែងតែជាធម្មជាតិ មានឬក៏គ្មានមិនសំខាន់ឡើយ។

ទោះបីគេមិនដែលបង្កើតនូវបរិយាកាសមិនល្អ ឬមួយក៏និយាយស្ដីអុកឡុករំខានចិត្តខ្ញុំ តែបើនិយាយពីថាមានអត្ថន័យអ្វីម្យ៉ាងនៅក្នុងជីវិតខ្ញុំ គឺគ្មាននោះទេ គ្រប់យ៉ាងគឺស្ងាត់ឈឹង សាបសូន្យ រហូតដល់ខ្ញុំបានចួបវណ្ណឌី។

«ខ្ញុំញ៉ាំឆ្អែតហើយ!»

ថាចប់ ខ្ញុំក្រោកឡើងមកបន្ទប់ទាំងស្រស់ស្រាយ ព្រោះជាពេលដែលខ្ញុំអាចឆែកទូរសព្ទមើលសារគេ។ វណ្ណឌីតែងផ្ញើមកខ្ញុំរាល់យប់ៗ តាមបែបជាមនុស្សដែលមានមនោសញ្ចេតនាឱ្យគ្នា។

ប៉ុន្តែយប់នេះ មិនឃើញគេផ្ញើសារមក ដាស់ចិត្តខ្ញុំឱ្យចេះតែមានអារម្មណ៍ចម្លែកថា មានរឿងអ្វីកើតឡើងចំពោះគេ?

ខ្ញុំមិនដឹងនោះទេថា ហេតុអ្វីគេជាមនុស្សដំបូងដែលខ្ញុំមានអារម្មណ៍ច្រាស់ច្រាល់បារម្ភ?

ពេញមួយយប់ ខ្ញុំគេងរង់ចាំសាររបស់គេរហូត គឺចាំដល់គេងលក់ ថែមទាំងសុបិនឃើញថាគេផ្ញើសារមក។ ព្រឹកឡើងខ្ញុំផ្ទៃកទូរសព្ទពិតជាឃើញគេផ្ញើសារមកមែន។

«យប់នេះមានរឿងមិនសប្បាយចិត្តខ្លាំង បើមានពេលទំនេរអាចចេញមកបានទេ? យើងជួបគ្នានៅកន្លែងដដែល ហើយនិយាយគ្នា!»

ឧទ្យានចាស់ក្បែរសាកលជាកន្លែងដែលខ្ញុំចួបគេដំបូង ក៏ជាទីកន្លែងសម្ងាត់ដ៏ពិសិដ្ឋសម្រាប់ខ្ញុំនិងគេ។

កាលណោះខ្ញុំឈឺពោះយ៉ាងខ្លាំង ទទួលបានប្រេងកូឡាពីគេ បន្ទាប់មកវាក្លាយជាទីកន្លែងដែលយើងចួបគ្នារហូត។ ប៉ុន្តែថ្ងៃនេះទឹកមុខរបស់គេពិតជាដូចគ្នាណាស់ ទៅនឹងជីវិតកន្លងមករបស់ខ្ញុំ។

វណ្ណឌីដ៏ស្រស់ស្រាយសុទិដ្ឋិនិយម ក្លាយជាមនុស្សដែលមានទុក្ខធំហួសនឹងបរិយាយចេញមក។ ទឹកមុខនេះគ្មានអ្នកណាយល់ប៉ុន្តែខ្ញុំខ្លួនឯងយល់ព្រោះខ្ញុំបានឆ្លងកាត់។

«មានរឿងអីទៅ?»

ទុក្ខគ្រាំក្នុងពិបាកទម្លាក់ចោលចេញមកណាស់ សូម្បីតែវណ្ណឌីគឺជាមនុស្សដែលមានចរិតសោមនស្សរីករាយ មានសកម្មភាពរស់រវើក មានទឹកមុខញញឹមប្រិមប្រិយនៅតែធ្លាក់ខ្លួននៅក្នុងទុក្ខមួយនេះ ខ្ញុំពិតជាមិនចង់ឃើញ និងថែមចង់ចែករំលែកជាមួយគេ។

មិនឮគេស្រដី ខ្ញុំតឿនបន្ថែម៖

«វណ្ណឌី មានរឿងអីមែនអត់?»

«មានរឿងមួយ ខ្ញុំយល់ថាគួរតែនិយាយប្រាប់ពៅ!»

គេថាហើយគេចភ្នែកចេញពីខ្ញុំ។

ខ្ញុំនៅស្ងៀម ព្រោះទ្រូងនេះទទួលអារម្មណ៍ថាឈឺៗនៅពេលដែលវណ្ណឌីមើលទៅដូចជាពិបាកដកដង្ហើមខ្ញុំក៏ពិបាកដកដូចគ្នា។ គេហាក់រងសម្ពាធអ្វីមួយ....ខ្ញុំនិយាយ៖

«បើនិយាយមិនសប្បាយចិត្ត ឌីមិនបាច់និយាយទេណា!»

«ខ្ញុំគិតពេញមួយយប់ហើយ ខ្ញុំចូលចិត្តពៅ....ហើយពៅ ....ជាមនុស្សសំខាន់សម្រាប់ខ្ញុំ! បើសិនជាថ្ងៃណាមួយ ខ្ញុំមានលទ្ធភាព ខ្ញុំប្រាកដជាចូលទៅដល់ឪពុកម្ដាយរបស់ពៅ ហើយធ្វើគ្រប់យ៉ាងឱ្យយើងបានរស់នៅជាមួយគ្នាជារៀងរហូតតទៅ!»

នេះជាលើកដំបូង ដែលអ្នកណាម្នាក់ បេះដូងយើងបញ្ចេញពាក្យថា«ចូលចិត្ត» បានមកនិយាយនៅនឹងមុខយើងមុតមាំ ទាំងដែលយើងមិនធ្លាប់សូម្បីស្រមៃថាជីវិតនេះ អាចមានរឿងល្អបែបនេះកើតឡើង។

ពាក្យសារភាព ធ្វើឱ្យរាងកាយយើងទាំងមូលកក់ក្ដៅ ត្រចៀកបានស្ដាប់ឮនូវពាក្យសន្យា ក៏ជាលើកដំបូងដែលវ័យប៉ុណ្ណេះទើបតែចេះមានស្នេហា ហើយបានចួបមនុស្សម្នាក់ដែលមកច្បាស់លាស់ជាមួយយើង ឯយើងក៏មានចិត្តលើគេវិញ....

«អ៊ុចឹង ចាំបាច់អីពិបាកចិត្តខ្លាំង? ខ្ញុំខំតែភ័យ!»

មិនមែនចប់ត្រឹមហ្នឹងដូចខ្ញុំគិតទេ គេនិយាយបន្តដោយស្រងូត៖

«មានរឿងខ្លះ ខ្ញុំចង់និយាយប្រាប់ពៅឱ្យហើយ!»

«ហេតុអីទៅ? ខ្ញុំមើលទៅឪដូចអត់សប្បាយចិត្ត! បើអ៊ុចឹង មិនចាំបាច់និយាយទេ! គេមិនចាំបាច់ស្ដាប់ក៏អត់អីដែរ!»

«មនុស្សស្រឡាញ់គ្នាត្រូវស្មោះត្រង់ចំពោះគ្នា!»

ពាក្យដែលគេនិយាយមកមួយម៉ាត់ចុងក្រោយនេះ ដូចជាអ្វីមួយធ្វើឱ្យខ្ញុំអណ្ដែតខ្លួនឯងឡើងទៅលើទប់ដៃជើងស្រាល និងចលនារាងកាយខ្លួនឯងមិនចង់បាន។ មានអារម្មណ៍ដូចជាខុសៗ មានអារម្មណ៍ដូចជាគេកំពុងតែថាឱ្យខ្ញុំ? ហើយការពិតដ៏សែនលំបាករបស់ខ្លួនឯងពេលនេះស្រោចស្រពមកលើខ្ញុំ។ មិនមែនតែគេជាមនុស្សរងសម្ពាធ គឺខ្ញុំជារងសម្ពាធធ្ងន់។ ខ្ញុំនេះហើយដែលជាអ្នកដែលកំពុងលាក់រឿងដ៏ធំមួយជាមួយគេ គេមិនដឹងការពិតផងថា ខ្ញុំជាអ្នកណា? រៀបការរួចហើយ ថែមទាំងមានគ្រួសារមួយដែលយើងទាំងពីរពិបាកសង្ឃឹមបានចួបគ្នា។

រឿងខ្ញុំជាច្រើនទៀត....ដែលគេគ្មានថ្ងៃដឹង។

ខ្ញុំនៅស្ងៀមក្ដាប់ម្រាមទាំង១០។ ប្រហែលជាទឹកមុខខ្ញុំផ្លាស់ បានជាគេកាន់តែមើលទៅពិបាកចិត្ត។

«ខ្ញុំគិតច្បាស់ហើយ គិតពេញមួយយប់! ខ្ញុំត្រូវតែនិយាយប្រាប់ពៅ!»

ខ្ញុំឈ្ងោកមុខទាំងស្លេកថ្គាល់ព្រោះ......ខ្ញុំកំពុងមានរឿងលាក់ច្រើនដែរ។

វណ្ណឌីនិយាយទៀត៖

«ខ្ញុំកំពុងចុះឈ្មោះរៀនជំនាញសហគ្រិន ខ្ញុំចង់ធ្វើជាអ្នករកស៊ី ចំណែករឿងការងារអ្វីខ្ញុំមិនចង់ឱ្យពៅសង្ឃឹមពេកនោះទេ! ខ្ញុំដឹងថា ពៅចូលចិត្តមនុស្សសុភាពស្លូតបូត ប៉ុន្តែខ្ញុំតាមពិតមានអតីតកាល....មួយ!»

«មិនបាច់និយាយទេ!» ខ្ញុំកាត់គេ ព្រោះអារម្មណ៍តឹងតែងជាសម្ងាត់មួយខ្សឹបប្រាប់បេះដូងនេះថា ជាអតីតកាលមិនល្អ ដែលធ្វើឱ្យគេអាម៉ាស់ឬក៏ឈឺចាប់ បានជាគេមានសភាពបែបនេះ។

រឿងនេះខ្ញុំយល់ ព្រោះខ្ញុំខ្លួនឯងក៏ដូចគ្នា។ ខ្ញុំកំពុងរស់នៅក្នុងអតីតកាលមួយដែលនៅបន្តមករហូតដល់ថ្ងៃដែលខ្ញុំកំពុងចួបគេ មិនដឹងថាថ្ងៃណា អតីតកាលនោះវិវត្តទៅជាអតីតពិតប្រាកដហើយលែងអន្ទោលមកតាមទៀត?

អនាគតកាលរបស់ខ្ញុំមានដែរទេ?

«...បើខ្ញុំមិនបាននិយាយ! ខ្ញុំធ្វើខុសចំពោះពៅ!» ខ្ញុំសម្លឹងមុខគេ ខ្ញុំមើលឃើញពីសេចក្ដីស្នេហាដ៏ជ្រាលជ្រៅមួយដែលខ្ញុំទើបតែស្គាល់ និងទើបតែទទួលបានក្នុងជីវិតនេះ គ្រប់យ៉ាងពិតជាបង្កប់នូវភាពស្រងេះស្រងោចនិងភាពអាម៉ាស់មួយយ៉ាងអាថ៌កំបាំង ដែលខ្ញុំដឹងខ្លួនខ្ញុំមិនបានស្មោះត្រង់ចំពោះគេផង ហេតុអីបានគេចេះតែទាមទារចង់ស្មោះត្រង់ជាមួយខ្ញុំ?

«ខ្ញុំធ្លាប់ជាប់គុក! ខ្ញុំមិនស្អាតស្អំ មិនអាចធ្វើលិខិតថ្កោលទោសដូចគេឯងបានទេពៅ! ប្រុសម្នាក់នៅចំពោះមុខពៅ មានសាវតារមិនល្អទេ! ថ្ងៃណាមួយទៅ ពៅគង់តែនឹងដឹង! ខ្ញុំធ្លាប់វាយ របួសកូនអ្នកជិតខាង ដែលមើលងាយប៉ាម៉ាក់ខ្ញុំ ហើយចុងក្រោយចោលរៀនទៅនៅក្នុងគុកជិតពីរឆ្នាំ!»

ខ្ញុំនៅស្ងៀម។ ស្ងៀមមិនហើបរួចមួយម៉ាត់ណាទាំងអស់ ទោះត្រចៀកខ្ញុំបានឮអ្វីៗគ្រប់យ៉ាងច្បាស់ៗ។ មនុស្សយើងគ្រប់គ្នា តែងមានអាថ៌កំបាំង ឬអតីតកាលមិនល្អណាមួយ ហើយខ្លះក៏បំភ្លេចចោលខ្លះក៏គាស់កកាយឡើងមក។

ពេលខ្ញុំនៅផ្ទឹងនេះ មិនទាក់ទងជាមួយការជាប់គុករបស់គេ មិនទាក់ទងជាមួយនឹងពាក្យសារភាពរបស់គេ ប៉ុន្តែទាក់ទងទៅនឹងអ្វីម្យ៉ាងរវាងយើងទាំងពីរ។ ខ្ញុំទ្រឹងព្រោះច្បាស់ដូចថ្ងៃព្រោះថាវណ្ណឌីគេមានសេចក្តីក្លាហានគ្រប់គ្រាន់ ក្នុងការយករឿងមិនសប្បាយចិត្តបំផុតនៃជីវិតរបស់គេមកប្រាប់ខ្ញុំ អតីតកាលដែលគេព្យាយាមបំភ្លេចបាត់ទៅហើយ គេសារភាពប្រាប់ខ្ញុំ ព្រោះមិនចង់ឱ្យថ្ងៃណាមួយខ្ញុំត្រូវដឹងវាដោយខ្លួនឯង ចុះខ្ញុំ? ពេលណា ទើបខ្ញុំអាចប្រាប់គេពីសមាសភាពពិតខ្ញុំទៅ?

ស្រាប់តែ....គេក្រោកចាកចេញ.....

ខ្ញុំងើបមុខស្នក់ៗសម្លឹងដំណើរមិនងាកក្រោយរបស់គេ។

គេកំពុងឈឺចាប់ណាស់ ដូចជាទទួលយកថា ខ្ញុំមិនអាចយល់ព្រមចំពោះអតីតកាលរបស់គេ។ ខ្ញុំមិនដឹងត្រូវធ្វើយ៉ាងណាទេ ខ្ញុំគឺស្លិតស្អិតនៅលើកៅអីនេះព្រោះអតីតរបស់ខ្ញុំ មិនមែនព្រោះរឿងរបស់គេឡើយ។ ចិត្តនេះ ខ្ញុំចង់រត់តាមគេ ចង់ប្រាប់គេវិញថា ខ្ញុំមិនមែនឈ្មោះពៅហើយខ្ញុំក៏មិនបានធ្វើការឱ្យថៅកែណាដែរ ខ្ញុំចង់ប្រាប់អតីតកាលទាំងអស់របស់ខ្ញុំ ប៉ុន្តែមាត់ខ្ញុំគាំង ហើយគេក៏ចាកចេញព្រោះយល់ខុស។

គេមិនងាកក្រោយ ដូចជាចង់ប្រាប់ថា រឿងយើងចប់ត្រឹមនេះចុះ ព្រោះខ្ញុំមិនអាចទទួលយកគេបាន វាប្រសើរជាងឱ្យគេទ្រាំលាក់លៀមចំពោះខ្ញុំ....ប៉ុន្តែ.....ព្រះ.....បេះដូងខ្ញុំទើបតែរស់ឡើងវិញបានប៉ុន្មានថ្ងៃប៉ុណ្ណោះ ក្រោយពីចួបគេ ខ្ញុំមិនអាចបាត់បង់គេដោយរបៀបនេះបានទេ។

....ការពិតទោះជាឈឺចាប់ប៉ុនណា ខ្ញុំចង់បានការពិត ដើម្បីបន្តដង្ហើមរស់នៅរបស់ខ្ញុំ ខ្ញុំរស់នៅក្លែងក្លាយពេញមួយជីវិតមកហើយ ខ្ញុំលែងចង់រស់នៅក្នុងជីវិតរបៀបមុនខ្ញុំចួបគេទៀតហើយ។

ខ្ញុំស្ទុះក្រោកដើរតាមទាំងស្រែកហៅ៖

«វណ្ណឌីៗ មិនមែនអ៊ីចឹងទេ កុំយល់ខុស!»

គេនៅតែដើរចេញ ខ្ញុំរត់តាមហើយហៅដដែលៗ រហូតដល់ទ្រាំលែងបានគេនៅស្ងៀមឈប់ដើរតែមិនបានងាកមកទេ។

គេមានសេចក្តីអាម៉ាស់ខ្ញុំយល់។

តែខ្ញុំអាម៉ាស់ជាង។ ខ្ញុំក្ដោបម្រាមដៃស្ដាំរបស់គេដែលម្ខាងទៀតនៅជ្រែងក្នុងហោប៉ៅខោ។

«ខ្ញុំមិនបានគិតអាក្រក់ ឬអន់ចិត្តអីពីអតីតកាលរបស់វណ្ណឌីទេ!»

«មិនមែនកំហុសរបស់ពៅទេ! គ្រាន់តែ ខ្ញុំយល់ថា គ្រួសារពៅប្រហែលជាមិនអាចទទួលយកខ្ញុំបាន!»

«ទេមិនមែនទេ! មិនទាក់ទងនឹងអ្នកណាទាំងអស់!»

គេងាកមកសម្លឹងភ្នែកខ្ញុំ។ ទំនងជាគេអាចមើលយល់ពីស្នេហារបស់ខ្ញុំចំពោះគេ អ៊ីចឹងហើយគេរឹតតែពិបាកចិត្ត នៅដំអក់ស្ដាប់ខ្ញុំ។ ខ្ញុំពន្យល់គេ៖

«តាមពិតមុននេះចង់ប្រាប់ឌីថា....គឺខ្ញុំខ្លួនឯង ក៏មានអតីតកាល! រឿងដែលយ៉ាប់ មកពីខ្ញុំកំសាក គឺខ្ញុំមិនអាចនិយាយចេញមកដូចឌី!»

គេដូចជាមើលឃើញទុក្ខសោកអាថ៌កំបាំងក្នុងភ្នែកខ្ញុំ គេហាមកនិយាយតិចៗ៖

«ទោះជាពៅពីមុនមកបានឆ្លងកាត់អ្វីខ្លះ ខ្ញុំទទួលយកពៅបានទាំងអស់!»

ទឹកភ្នែកខ្ញុំស្រក់ពេលយើងសម្លឹងគ្នា។ ចិត្តនេះ ខ្ញុំចង់និយាយប្រាប់គេណាស់ ថាមិនមែនពីមុនទេ គឺបច្ចុប្បន្នកាល អតីតគេចប់ទៅហើយ នៅឡើយអតីតរបស់ខ្ញុំ វានៅអន្ទោលជាប់ជាមួយរាងកាយខ្ញុំនៅឡើយ។ គ្រប់យ៉ាងដែលខ្ញុំធ្លាប់ប្រាប់ ឈ្មោះខ្ញុំ ការងារជាអ្នកបម្រើថៅកែស្រីហាងលក់ខោអាវប្រេន គ្រប់យ៉ាងសុទ្ធតែក្លែងក្លាយ។

ប៉ុន្តែមាត់ខ្ញុំ បែរជានិយាយផ្សេង....

«ពិតមែន?»

គេមិនឆ្លើយ ហើយបែរខ្លួនមកកាន់ដៃខ្ញុំទាំងសងខាង។ រាងកាយពួកយើងប្រឈមគ្នាជាមួយការដង្ហោយហៅនៃបេះដូងពីរ ត្រូវការគ្នាពេកហើយ។

«ពៅជាមនុស្សស្រីដែលខ្ញុំស្រឡាញ់! ជាមនុស្សដែលខ្ញុំចង់ការពារ! ចង់នៅក្បែរពៅរហូតទៅ!»

នោះគឺជាព្រឹកមួយ ដែលពីរនាក់យើងបាននិយាយត្រូវរ៉ូវនិងយល់ចិត្តគ្នាជាងពេលណាៗទាំងអស់។ អារម្មណ៍អង្គុយក្បែរមនុស្សដែលយើងស្រឡាញ់ នៅក្រោមធម្មជាតិ មិនមាត់មិនកស្ដាប់សូម្បីតែសន្ទឹកខ្យល់និងសូរសំឡេងសត្វយំ ស្រូបក្លិនផ្កាជាមួយគ្នា នេះហើយគឺជាជីវិត

ដែលខ្ញុំត្រូវការ ជាជីវិតដ៏មានសុវត្ថិភាពសូម្បីតែគ្រប់ការដកដង្ហើមក៏មានអារម្មណ៍ថាស្រណុកសុខស្រួល។

នៅក្បែរមនុស្សដែលអង្គុយដើម្បីយើង គិតអំពីយើងហើយស្រមៃឃើញអនាគតមួយដែលដាក់យើងទៅជាមួយគ្នា គិតពីអារម្មណ៍របស់យើង វិនិយោគភាពស្មោះត្រង់របស់គេមកលើយើង ជាអ្វីដែលខ្ញុំទើបនឹងមាន។

ខ្ញុំលាវណ្ណឌីត្រលប់មកផ្ទះវិញ។

នៅលើឡានជាមួយពូតែកុង មួយចប់ផ្លូវខ្ញុំបានសម្រេចចិត្ត។

ដើរកាត់អាងទឹក ខ្ញុំឃើញប្តីខ្ញុំបងតារា ដែលកំពុងតែជ្រមុជទឹក ស្រែកហៅខ្ញុំឱ្យចុះ ងូតទឹកជាមួយគ្នា។ ប្រហែលជាគាត់ឃើញខ្ញុំញញឹមស្រស់ស្រាយ បានជាប្តីខ្ញុំថ្លោះទឹកមុខឆ្ងល់សម្លឹងមកខ្ញុំដូចជាចម្លែកក្នុងចិត្ត។

ខ្ញុំល្ងង់ណាស់ដែលមិនដឹងថាមួយរយៈមកនេះមនុស្សជុំវិញខ្លួនខ្ញុំ ចាប់ផ្តើមសម្គាល់ដឹងនូវអាកប្បកិរិយាប្លែករបស់ខ្ញុំ ប៉ុន្តែពេញមួយយប់នោះខ្ញុំពិតជាបានគិតនិងសម្រេចចិត្តរួចរាល់ហើយមែន។

ទោះបីជាប្តីខ្ញុំព្យាយាមលួងលោមយ៉ាងណា ខ្ញុំមិនបន្តជីវិតក្លែងបន្លំមួយនេះទៀតឡើយ។

គេគោះទ្វារហើយឱបខ្នើយចូលមក....

«យើងខានគេងជាមួយគ្នាច្រើនខែហើយ!»

ខ្ញុំឈរស្តុបស្រពោន។ យើងមិនដែលប៉ះពាល់គ្នាយូរមកហើយ។ សូម្បីតែរឿងកូនរលូតនោះ ជារឿងកើតឡើងដោយចៃដន់សុទ្ធសាធ នាយប់ដែលខ្ញុំស្រវឹងជ្រុលម្នាក់ឯង មិនដឹងហេតុអ្វីបងតារាអាចបីខ្ញុំចូលមក ហើយឆ្លៀតពេលនោះ ទាមទារសិទ្ធិជាប្តីលើខ្ញុំ ទាំងដឹងហើយថា ខ្ញុំមិនដែលស្រឡាញ់គាត់ទេ។

តាំងពីថ្ងៃរៀបការដំបូងៗខ្ញុំតែងបញ្ជាក់នឹងគាត់ថា ខ្ញុំមិនបានស្រឡាញ់ ហើយអាពាហ៍ពិពាហ៍នេះត្រឹមជារឿង business រវាងប៉ាខ្ញុំនិងប៉ាគាត់ មុនក្រោយយើងគង់តែដល់ទីបញ្ចប់ជាមួយគ្នា។

ចំណែកគាត់ក៏មិនដែលខ្វីតាមអង្វរខ្ញុំដែរ គឺចាំឱ្យខ្ញុំព្រមដោយខ្លួនឯង។ បងតារាមានស្រីស្អាតៗជាច្រើននៅខាងក្រៅ តាមសភាពជាបុរសសង្ហានិងមានលុយច្រើន ប៉ុន្តែរឿងនេះមិនដែលធ្វើឱ្យខ្ញុំប្រចណ្ឌឬទាមទារកាតព្វកិច្ចអ្វីទាំងអស់។

ព្រោះថា....ខ្ញុំជាមនុស្សគ្មានបេះដូងទេតាំងពីដើមមក។

ទើបតែពេលនេះ យប់នេះ ខ្ញុំមានវណ្ណឌីស្ពាយមកតាមបេះដូងមួយនេះ ខ្ញុំដឹងថា បេះដូងខ្ញុំត្រូវសង្គ្រោះឱ្យរស់ឡើងវិញ ហើយអ្នកដែលប៉ះពាល់ខ្ញុំ គួរតែជាមនុស្សតែម្នាក់គត់ដែលបេះដូងខ្ញុំត្រូវការ។

«គេងដូចមុនទៅ!»

ខ្ញុំប្រុងបិទទ្វារ តែគាត់ឃាត់មួយទំហឹងដៃ។

«បងមិនយល់ទេ ប៉ុន្មានថ្ងៃនេះអូនឯងធ្វើអីខ្លះ? យើងជាប្ដីប្រពន្ធ កូនយើងរលូតយូរហើយ បើយើងនៅតែអ៊ីចឹងកាលណា យើងមានកូនវិញបាននឹងគេ!»

កុំថាឡើយមានកូនជាមួយគ្នា ខ្ញុំថែមទាំងមានបំណងច្បាស់ ក្នុងការបញ្ចប់រឿងរ៉ាវរវាងគេហើយនិងខ្ញុំត្រឹមពេលនេះ។

គឺកាន់តែឆាប់កាន់តែល្អ។

គ្រប់យ៉ាងដែលខ្ញុំធ្វើ គឺដើម្បីមនុស្សម្នាក់ដែលបានសង្គ្រោះបេះដូងខ្ញុំឱ្យលោតឡើងមកវិញ ហើយគេបានស្មោះត្រង់ចំពោះខ្ញុំជាងដែលខ្ញុំស្មោះត្រង់ចំពោះគេ។

«យើងលែងគ្នាទៅបងតារា!»

ខ្ញុំនិយាយខ្លីៗខ្សឹបៗមិនចង់ឱ្យឆ្អើលអ្នកផ្ទះ។

«ហើយ....បងយកអ្វីក៏ដោយ បងយកចុះ! បងយកទាំងអស់ទៅ! ខ្ញុំទៅតែខ្លួន!»

ប្រហែលជាគាត់ភាំងនឹងពាក្យស្នើនេះ បានជានៅស្ងៀមបន្តិចហើយរុញខ្ញុំចូលមកក្នុងកាយវិការមិនចង់ឱ្យពាក្យទាំងនេះក្នុងយប់នេះក្លាយជាពាក្យអេចអូចសម្រាប់ក្រុមមនុស្សនៅផ្ទះបាយ។

«អូនឯងកើតអីរីជា?»

«ខ្ញុំចង់លែងលះគ្នា!»

ទោះគាត់បិទទ្វារហើយ ក៏ខ្ញុំនៅតែនិយាយដោយស្មោះ ជាសម្តីស្រែកឃ្លានសេរីភាពចេញមកពីក្នុងចិត្តដោយមិនបានរារែក មិនបានសោកស្តាយ។

បងតារាមិនមែនស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏មិនស្រឡាញ់គាត់។

មនុស្សផ្ទះនេះ ជាច្រើនជំនាន់មកហើយគឺរស់នៅរបៀប Business បែបនេះឯង រៀបការដោយមិនបាច់ស្រឡាញ់ បង្កើតកូន បន្តពូជពង្សនិងរៀបការដោយរៀបចំទៀត ទៅកាន់អ្នកណាមួយមកពីគ្រួសារពាក់ព័ន្ធជំនួញជាមួយគ្នា។

ពាក្យស្នើនេះ បងតារាគួរយល់ហើយថា ខ្ញុំបាននិយាយចេញពីបេះដូងរបស់ខ្ញុំ ជាបេះដូងដ៏រឹងមាំមួយដែលទើបតែក្រោកមកវិញក្រោយពីការសន្លប់ ជាបេះដូងរុក្ខជាតិអស់ជាច្រើនឆ្នាំ។

ពេលដែលខ្ញុំនិយាយនិងសម្លឹងមុខគាត់ចំៗ ទោះបីជាសម្តីរបស់ខ្ញុំទន់ភ្លន់តាមរបៀបចរិតលក្ខណៈធម្មជាតិខ្ញុំ ប៉ុន្តែគ្រប់គ្នាក្នុងផ្ទះដឹងថា ខ្ញុំមិននិយាយលេងទេ។ ពាក្យពេចន៍ដែលខ្ញុំនិយាយមក គឺខ្ញុំតាំងចិត្ត និងច្បាស់លាស់ណាស់។

«ឆ្កួតហើយ! គេងទៅ!»

គេនិយាយប្រាប់ខ្ញុំដោយគេចៗ។

ខ្ញុំដឹងថា បងតារា ប៉ា និងប៉ាម៉ាក់ក្មេកខ្ញុំគ្មានថ្ងៃព្រមនោះទេ តែខ្ញុំលែងទ្រាំរស់នៅ រង់ចាំការយល់ព្រមពីអ្នកណាទៀតហើយ។

ខ្ញុំចាប់ផ្តើមនិយាយម្តងទៀត៖

«យើងមិនដែលស្រឡាញ់គ្នាទេ! បងក៏ដឹង ខ្ញុំក៏ដឹង!»

«តែឥឡូវ....បងស្រឡាញ់អូនខ្លាំងវីដា! គិតចិត្តមនុស្សម្នាក់ដែលនៅជាមួយអូនយូរមកហើយ កុំធ្វើតាមតែអារម្មណ៍ហើយបំផ្លាញបងនិងប៉ាម៉ាក់!»

«នេះជាការសម្រេចចិត្តដ៏ល្អសម្រាប់ទាំងអស់គ្នា! ដោះលែងខ្លួនឯងពីជីវិតបោកប្រាស់នេះទៅបងតារា!» ខ្ញុំនិយាយទាំងមិនសោកស្តាយ។

«គេងទៅ ស្អែកបងនាំទៅពេទ្យ!»

គាត់គិតថាខ្ញុំឈឺ ឬយកពាក្យនេះមកគម្រាមខ្ញុំ? ខ្ញុំមិនព្រេចភ្នែកចំពោះពាក្យគំរាមរបស់គេទៀតនោះទេ មនុស្សដែលរស់នៅក្នុងសភាពខ្ទេចខ្ទាំជាយូរមកហើយម្នាក់នេះ ឈប់ឱ្យអ្នកណា

ម្នាក់មកសម្លុតឬក៏បង្កើតសម្ពាធជីវិតឱ្យទៀតហើយ។ យ៉ាងហោចណាស់នៅពិភពលោកខាងក្រៅ ទោះបីថាគ្មានអ្វីសោះ គ្មានកិត្តិយស គ្មានប្ដីជាCEO វណ្ណឌីមិនស្រស់សង្ហា ប្រើសម្លៀកបំពាក់ថ្លៃកប់ពពក យើងគ្មានអ្នកបម្រើអាហារ តែរបស់ទាំងអស់នេះខ្ញុំបានទទួលមកតាំងពីកំណើត ហើយដើម្បីរក្សាវា ខ្ញុំក៏បានបាត់បង់រឿងផ្សេងធំមួយទៀតដែលបេះដូងខ្ញុំចង់បាន។ ខ្ញុំមិនដូរសុភមង្គលជាមួយរបស់ទាំងនេះទៀតទេ។

ប្រសិនបើខ្ញុំដោះដូរវាជាមួយនឹងការរស់ឡើងវិញនៃបេះដូងខ្លួនឯងម្ដងទៀត លើកនេះខ្ញុំនឹងស្លាប់ទៅជារៀងរហូតហើយ។

ខ្ញុំនិយាយដាច់ណាត់៖

«ស្អែកនេះ ខ្ញុំនឹងពិភាក្សាជាមួយមេធាវីថាត្រូវធ្វើយ៉ាងណាចំពោះរឿងនេះ!»

«កុំសង្ឃឹមឱ្យសោះ បងមិនលែងអូនទេ!»

គេនិយាយពីក្រោយខ្នងខ្ញុំនៅពេលដែលខ្ញុំឱបខ្នើយដើរចេញក្រៅ។ ពេញមួយផ្ទះនេះអ្នកណាក៏ដឹងពីចំណងអាពាហ៍ពិពាហ៍លេងសើច របស់ពួកយើងដែរ។ ឈរគិតនៅមាត់ទ្វារ ខ្ញុំដឹងថា ប្រតិកម្មខ្ញុំយប់នេះលឿនបន្តិច សម្រាប់ឱ្យបងតារាយល់ព្រម ប៉ុន្តែមុនហើយនឹងក្រោយទេ។

សេចក្ដីក្លាហាននិងការឈឺចាប់ទាំងប៉ុន្មាននៅក្នុងសួនឧទ្យាន ដែលវណ្ណឌីទម្លាយប្រាប់រឿងអតីតកាលដ៏ជូរចត់របស់គេមក បានដាស់ខ្ញុំថា គេធ្វើបាន ហេតុអីបានជាការពិតមួយដែលខ្ញុំគួរតែធ្វើ មុននិងក្រោយខ្ញុំធ្វើមិនបាន?

ខ្ញុំឈានចាកចេញពីបន្ទប់នោះមកទាំងញញឹម។

បេះដូងខ្ញុំប្រាប់ថា ខ្ញុំកំពុងធ្វើបានល្អបំផុតហើយក្នុងនាមមនុស្សម្នាក់ ដែលស្មោះត្រង់ចំពោះខ្លួនឯងនិងស្មោះត្រង់ចំពោះគ្រប់គ្នានៅលើលោកនេះ។ ទោះយ៉ាងណា ខ្ញុំមិនដឹងថា បន្ទាប់ពីយប់ដែលយើងបាននិយាយគ្នានោះ ប្ដីខ្ញុំបានចាប់ផ្ដើមតាមដានខ្ញុំ ហើយមិនយូរមិនឆាប់ គេបានរកឃើញ រឿងរ៉ាវរបស់ពួកយើង.....

តើជាតិនេះពីរនាក់ខ្ញុំចួបគ្នាដែរទេ?

ខ្ញុំរង់ចាំនៅយោបល់របស់មិត្តអ្នកអាននៅខាងក្រោមនេះសិន មុនពេលដែលដាក់ជូនបន្តនូវនិទានភាគទីពីររបស់វណ្ណឌីនិងវីជាក្រោមចំណងជើងថា«**ព្រោះបេះដូងនេះនៅមានអូន**!»។